ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងកម្មវិធី "ខួប ៣០ឆ្នាំ នៃការបង្កើតសមាគមធនាគារនៅកម្ពុជា"

ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

**សូមគោរព ៖**

- **លោក វ័ន្ត សោភ័ណ តំណាងសមាគមធនាគារនៅកម្ពុជា**
- **លោកជំទាវ ឌិត នីតា តំណាងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកប្បការ ដែលបានចូលរួមជាអធិបតីជាមួយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ក្នុងកម្មវិធី "ខួប ៣០ឆ្នាំ នៃការបង្កើតសមាគមធនាគារនៅកម្ពុជា" នាពេលនេះ។

ខ្ញុំនៅចាំបានថា សមាគមធនាគារនៅកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាស្ថាប័នផ្លូវការ ដែលតំណាងឱ្យវិស័យធនាគារក្នុងប្រទេសកម្ពុជា។ ការបង្កើតសមាគមនេះ គឺក្នុងគោលបំណងជំរុញការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា និងការពារផលប្រយោជន៍ស្របច្បាប់របស់គ្រឹះស្ថានជាសមាជិក ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរក្នុងស្រុក និងអន្តរជាតិ សមាគម អង្គការ និងស្ថាប័នពាក់ព័ន្ធ និងដើរតួនាទីជាអ្នកសម្របសម្រួលរវាងគ្រឹះស្ថាន និងធនាគារជាតិនៃកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចូលរួមអបអរសាទរ និងកោតសរសើរចំពោះក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងបុគ្គលិកសមាគមធនាគារនៅកម្ពុជា ក្នុងការបំពេញមុខងាររបស់ខ្លួន និងសម្រេចបាននូវលទ្ធផលដូចពេលនេះ ព្រមទាំងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា នារយៈពេល ៣០ឆ្នាំ កន្លងមក។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!**

ក្នុងរយៈពេល ៣០ឆ្នាំ នេះ ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបន្តរក្សាបាននូវភាពធន់ និងបោះជំហានទៅមុខជាលំដាប់ ក្នុងការរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ច។ ទន្ទឹមនេះ ការបន្តកើនឡើងនូវទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើ នៅក្នុងប្រព័ន្ធធនាគារ គឺបានបង្ហាញយ៉ាងច្បាស់នូវជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិន មកលើប្រព័ន្ធធនាគារ និងការងើបឡើងវិញនៃសេដ្ឋកិច្ចនៅកម្ពុជា។

ជាមួយនឹងការរីកចម្រើននេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ តែងតែយកចិត្តទុកដាក់ជាប្រចាំក្នុងការតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានរួមចំណែកគាំទ្រដល់ឌីជីថលូបនីយកម្មសេដ្ឋកិច្ច-សង្គមកម្ពុជា ក៏ដូចជា សម្រួលដល់សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍនិងធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាបន្តបន្ទាប់ ដូចជា ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធធនាគារអនឡាញ ប្រព័ន្ធរីផែលផេ ប្រព័ន្ធខេមបូឌានស៊ែស្វិច ជាពិសេស ប្រព័ន្ធបាគង ដែលជួយសម្រួលដល់អ្នកប្រើប្រាស់រួមទាំងធុរជន ក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ ក៏ដូចជាការទូទាត់ក្នុងស្រុក និងការទូទាត់ឆ្លងដែនតាមខេអេចឃ្យូអរកូត ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងចំណាយប្រតិបត្តិការទាប។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បានតភ្ជាប់ប្រព័ន្ធទូទាត់ទៅកាន់ប្រទេសមួយចំនួន ដូចជា ថៃ ម៉ាឡេស៊ី ឡាវ ចិន និងវៀតណាម ជាដើម ដើម្បីជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍។

វឌ្ឍនភាពទាំងនេះ បានចូលរួមយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ជាក់ស្តែង យោងតាមលទ្ធផលស្រាវជ្រាវ Mobile Tracker Survey របស់មូលនិធិ UNCDF បានបង្ហាញថា អត្រាអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានការកើនឡើងគួរឱ្យកត់សម្គាល់ពី ៥៩% ក្នុងឆ្នាំ២០១៥ ដល់ ៦៧% ក្នុងឆ្នាំ២០២១ ដែលខិតជិតនឹងគោលដៅ ៧០% ត្រឹមឆ្នាំ២០២៥។ ជាមួយគ្នានេះ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ក៏ជាការងារស្នូលមួយរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាបាននូវភាពរឹងមាំ ភាពធន់ និងចីរភាព ព្រមទាំងបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិន មកលើប្រព័ន្ធធនាគារបន្ថែមទៀត។ ក្នុងនោះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រសួង-ស្ថាប័ននិងដៃគូអភិវឌ្ឍជាច្រើន ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ដូចជាចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ព្រមទាំងបានយកចិត្តទុកដាក់

លើកិច្ចការពារអតិថិជន តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិដើម្បីពង្រឹងប្រសិទ្ធិភាពនៃការការពារសិទ្ធិរបស់អតិថិជន និងការបង្កើតក្រុមការងារដើម្បីទទួលនិងដោះស្រាយបណ្ដឹងអតិថិជន ជាដើម។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ដើម្បីឱ្យរាល់សកម្មភាពដែលបានលើកឡើងខាងលើទទួលបាននូវលទ្ធផលកាន់តែល្អប្រសើរ គឺទាមទារការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធ ដូចជា សមាគមធនាគារនៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរដល់សមាគមធនាគារនៅកម្ពុជា ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន តាមរយៈការគាំទ្រការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ការរៀបចំវេទិកាពិភាក្សានិងវគ្គបណ្ដុះបណ្ដាល ការបង្កើតជាវីដេអូអប់រំ ការរៀបចំយន្តការដោះស្រាយបណ្ដឹងអតិថិជន ការដាក់ឱ្យដំណើរការនូវក្រមប្រតិបត្តិ សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ ការពង្រឹងការអនុវត្តតាមស្តង់ដារកិច្ចសន្យាឥណទាន និង ខចែងស្តង់ដារនៃកិច្ចសន្យាឥណទាន ជាដើម។ ជាមួយគ្នានេះ ការចុះអនុស្សរណៈយោគយល់គ្នា រវាងសមាគមធនាគារនៅកម្ពុជា និងសារមន្ទីរព្រះស្រីល្បសានវរ្ម័ន ក្រោមការគាំទ្រពីធនាគារជាតិនៃកម្ពុជា កាលពីខែមីនា កន្លងទៅ ក៏បង្ហាញផងដែរពីការចូលរួមលើកស្ទួយការអប់រំផ្នែកហិរញ្ញវត្ថុ និងការស្វែងយល់ពីប្រវត្តិសេដ្ឋកិច្ច និងរូបិយវត្ថុនៅកម្ពុជា។

បើទោះជាយ៉ាងនេះក៏ដោយ ខ្ញុំក៏សូមស្នើឱ្យសមាគមធនាគារនៅកម្ពុជា៖

- បង្កើនការយកចិត្តទុកដាក់លើកិច្ចការពារផលប្រយោជន៍រួមរបស់សមាជិក
- បុរេសកម្មក្នុងការបញ្ចេញព័ត៌មានល្អៗ និងបង្កើនការយកចិត្តទុកដាក់លើការឆ្លើយតបភ្លាមៗ ចំពោះព័ត៌មានដែលមិនត្រឹមត្រូវ ឬដែលមានផលប៉ះពាល់អវិជ្ជមានដល់វិស័យធនាគារ
- បង្កើនកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចការពារអតិថិជន និងដោះស្រាយបណ្ដឹងអតិថិជនឱ្យមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងក្រមប្រតិបត្តិសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ និងការរីកចម្រើនប្រកបដោយបរិយាបន្ន និង

- ពង្រឹងការកសាងសមត្ថភាពមន្ត្រីបុគ្គលិករបស់គ្រឹះស្ថាននីមួយៗ និងសមាគមធនាគារនៅកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងការអបអរសាទរសារជាថ្មី ចំពោះសមិទ្ធផលគួរជាទីមោទនៈ ដែលសមាគមធនាគារនៅកម្ពុជាសម្រេចបាននារយៈពេល ៣០ឆ្នាំ កន្លងមកនេះ និងសូមជូនពរដល់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់សមាគមធនាគារនៅកម្ពុជា សូមមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជួបនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**